ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់

លេខ : ៤៧ ភដសសរ

# សេចក្តីសំរេច
## ស្តីពី
## ការបង្កើតប្រព័ន្ធទទួល និងដោះស្រាយបណ្តឹង សំរាប់គំរោងរៀបចំដែនដី និងរដ្ឋបាលដីធ្លី

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃ ទី ២៣ ខែ មិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃ ទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង រៀបចំ ដែនដី នគរូបនីយកម្ម និងសំណង់
- យោងតាមការចាំបាច់របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

## ស ម្រេ ច

**ប្រការ ១.-**

ត្រូវបានបង្កើតប្រព័ន្ធទទួល និងដោះស្រាយបណ្តឹងសំរាប់គំរោងរៀបចំដែនដី និងរដ្ឋបាលដីធ្លី ដោយកំណត់ពីរបៀបប្តឹង របៀបទទួលបណ្តឹង និងនីតិវិធីដោះស្រាយបណ្តឹងពាក់ព័ន្ធនិងការងារចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ ការងារលទ្ធកម្ម និងការងារហិរញ្ញវត្ថុ ។

**ប្រការ ២.-**

គំរោងរៀបចំដែនដី និងរដ្ឋបាលដីធ្លី ត្រូវបង្កើត ៖

- ប្រអប់សំបុត្រសំរាប់ទទួលពាក្យប្តឹងដាក់នៅគ្រប់ការិយាល័យអនុវត្តគំរោងខេត្ត-ក្រុង និង នៅទីស្តីការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

អាស័យដ្ឋាន លេខ ៧៧១-៧៧៣ មហាវិថី ព្រះមុនីវង្ស សង្កាត់បឹងត្របែក ខ័ណ្ឌចំការមន រាជធានីភ្នំពេញ
MLMUPC Tel/Fax: (855-23) 215 660, E-mail : mlmupc@camnet.com.kh ; LMAP Tel\Fax: (855-23) 211 354, E-mail : lmap@camnet.com.kh

343

- ខ្សែទូរស័ព្ទពិសេស[១] ដាក់នៅទីចាត់ការកណ្តាលនៃគំរោងរៀបចំដែនដី និងរដ្ឋបាលដីធ្លីដោយមានអ្នកប្រចាំការចំនួន ០២រូប នៅរៀងរាល់ម៉ោងធ្វើការដើម្បីទទួល កត់ត្រា ថតសំលេងបណ្តឹង អនុសាសន៍ផ្សេងៗរបស់អតិថិជនទុកជាមូលដ្ឋានសំរាប់ការបកស្រាយបំភ្លឺ ។

ប្រការ ៣.-

អំពីបណ្តឹង និងការដាក់ពាក្យប្តឹង ៖-

សាធារណជនអាចប្តឹងផ្ទាល់មាត់ តាមទូរស័ព្ទ ឬដាក់ពាក្យប្តឹងជាលាយលក្ខណ៍អក្សរក្នុងការតវ៉ា ឬការផ្តល់អនុសាសន៍ផ្សេងៗទៅគំរោងរៀបចំដែនដី និងរដ្ឋបាលដីធ្លី ឬទៅក្រសួងផ្ទាល់ ។ ករណីមានសំណូមពរអ្នកទទួលបណ្តឹងត្រូវតែរក្សានូវអនាមិកភាពរបស់អ្នកប្តឹង ប៉ុន្តែអ្នកប្តឹងត្រូវផ្តល់ព័ត៌មានដោយមានភស្តុតាងគ្រប់គ្រាន់ដើម្បីជាមូលដ្ឋានក្នុងការពិចារណាឱ្យបានគ្រប់ជ្រុងជ្រោយ ។

ប្រការ ៤.-

អំពីយន្តការទទួល និងដោះស្រាយបណ្តឹង

យន្តការទទួល និងដោះស្រាយបណ្តឹងមាន ០២ថ្នាក់ ៖

១. គណៈកម្មការទទួល និងដោះស្រាយបណ្តឹងថ្នាក់កណ្តាលដឹកនាំដោយនាយកគំរោងរៀបចំដែនដី និងរដ្ឋបាលដីធ្លី ។ សមាជិកគណៈកម្មការនេះមួយចំនួនជ្រើសរើសពីក្នុងជួរថ្នាក់ដឹកនាំគំរោង និងមួយចំនួនទៀតពីក្នុងជួរមន្ត្រីពាក់ព័ន្ធនឹងការងារចុះបញ្ជីដីធ្លី ការងារលទ្ធកម្ម ការងារហិរញ្ញវត្ថុ ការងារសេវាកម្ម ការងារបុគ្គលិក ។ ចំពោះសវនករផ្ទៃក្នុងរបស់គំរោងមានតួនាទីជាសមាជិកសង្កេតការណ៍ ។ ក្នុងករណីដែលភាគីបណ្តឹងមិនពេញចិត្តនឹងលទ្ធផលដែលគណៈកម្មការបានសំរេច ភាគីបណ្តឹងអាចប្តឹងទៅថ្នាក់ដឹកនាំក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ។

២. អនុគណៈកម្មការទទួល និងដោះស្រាយបណ្តឹងថ្នាក់ខេត្ត-ក្រុងអនុវត្តគំរោងដឹកនាំដោយនាយកចាត់ការគំរោងខេត្ត-ក្រុង អនុប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ខេត្ត-ក្រុង ទទួលបន្ទុកការងារពិនិត្យគុណភាពបច្ចេកទេសជាអនុប្រធាន និងប្រធានវាលជាសមាជិក ។ ក្នុងករណីដែលភាគីបណ្តឹងមិនពេញចិត្តនឹងលទ្ធផលដែលអនុគណៈកម្មការបានសំរេច ភាគីបណ្តឹងអាចប្តឹងទៅប្រធានគណៈកម្មការរដ្ឋបាល ។

ប្រការ ៥.-

អំពីនីតិវិធីនៃការដោះស្រាយបណ្តឹងសំរាប់ គណៈកម្មការថ្នាក់កណ្តាល ៖

(១) ខ្សែទូរស័ព្ទពិសេស គឺជាខ្សែទូរស័ព្ទដែលអ្នកហៅចូលមិនអស់ប្រាក់